**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :.................៣៧៦/១៤.........**ក.ប**/ស.ស.រ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍ប្រចាំស្ថានទូតកម្ពុជានៅទីក្រុងបាងកក

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នសរកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញសេចក្តីជូនដំណឹងលេខ ១២៤៥ សជណ.អវ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញប្រកាសលេខ ២២៥ ក.ប/ប្រ.ក ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងប្រកាសអន្តរក្រសួង លេខ ២៥៧៤ ប្រក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីនីតិវិធី និងបែបបទនៃការផ្តល់លិខិតឆ្លងដែនធម្មតាជូនពលករ-ពលការិនីខ្មែរទៅធ្វើការដោយស្របច្បាប់នៅបរទេស របស់ក្រសួងមហាផ្ទៃ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## សម្រេច

ប្រការ ១.-

ត្រូវបានបង្កើត លេខាធិការដ្ឋានអចិន្ត្រៃយ៍ប្រចាំស្ថានទូតកម្ពុជានៅទីក្រុងបាងកក ដែលមានសមាសភាពដូចខាងក្រោមៈ

| | | |
|---|---|---|
| ១. ឯកឧត្តម **សេង សក្ដា** | អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| ២. ឯកឧត្តមឧត្តមសេនីយ៍ឯក **ខុច ផល្លី** | អគ្គនាយករងនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ | អនុប្រធានប្រចាំការ |



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

៣. ឯកឧត្តម **ហេង សួរ** អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងជានាយកខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុប្រធាន

៤. ឯកឧត្តមឧត្តសេនីយ៍ឯក **នៅ លក្ខណា** អគ្គនាយករងនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ អនុប្រធាន

៥. លោក **ជៀម ឡាម៉ាទីន** ទីប្រឹក្សាទទួលបន្ទុកការងារពលករនៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍ សមាជិក

៦. លោក **សេដ្ឋា វឌ្ឍនា** ជំនួយការខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីសុខ អាន សមាជិក

៧. លោក **គឹម ចំរើន** ទីប្រឹក្សាក្រសួង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

៨. លោក **ឃីម សុសំរេច** ប្រធានលេខាធិការដ្ឋាននៃអគ្គនាយកដ្ឋានការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

៩. លោក **មុី ចន្ទវិសាល** អនុប្រធានការិយាល័យនៃអគ្គនាយកដ្ឋានការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

១០. លោកអនុសេនីយ៍ឯក **ស្រី ពីសី** មន្ត្រីនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ សមាជិក

១១. លោកអនុសេនីយ៍ត្រី **ឡាយ ម៉ុនរៀង** មន្ត្រីនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ សមាជិក

**ប្រការ ២.-**

លេខាធិការដ្ឋាននេះ មានភារកិច្ចដូចតទៅ៖

- សហការជាមួយឯកអគ្គរាជទូតកម្ពុជាប្រចាំទីក្រុងបាងកក ដើម្បីសម្រួលនីតិវិធីជាមួយភាគីថៃក្នុងការបំពេញបេសកកម្មផ្តល់ភាពស្របច្បាប់ជូនពលករកម្ពុជាតាមគោលការណ៍ជាធរមាន
- គ្រប់គ្រង និងសម្របសម្រួលការងាររបស់ក្រុមការងារអន្តរក្រសួងចល័ត និងក្រុមការងារបោះពុម្ពលិខិតឆ្លងដែន
- ទទួលបន្ទុកកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- ធ្វើរបាយការណ៍ប្រចាំសប្តាហ៍ជូនប្រធានគណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅព្រះរាជាណាចក្រថៃឡង់ដ៍
- និងការងារផ្សេងទៀតតាមការចាំបាច់។

**ប្រការ ៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ២០១៤

រដ្ឋមន្ត្រី

**អ៊ិត សំហេង**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ក្រសួងមហាផ្ទៃ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ដូចប្រការ៣
- ឯកសារ-កាលប្បវត្តិ